**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...១៦៧...អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" លើផ្ទៃដីទំហំ៤១,៥៣ហិកតា ស្ថិតក្នុងភូមិសាស្ត្រ ភូមិទទឹងថ្ងៃ ឃុំបឹងទូក និងទំហំ៧,០៧ហិកតា ក្នុងភូមិព្រែកចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់ជាតំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" លើផ្ទៃដីទំហំ៤១,៥៣ ហិកតា (សែសិបមួយហិកតានិងហាសិបបីអា) សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានស្ថិតក្នុងភូមិសាស្ត្រភូមិទទឹងថ្ងៃ ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ដែលមានផែនទីកំណត់ទីតាំងជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងចំណុចនិយាមកាដូចខាងក្រោម៖

| No | X | Y | No | X | Y |
|---|---|---|---|---|---|
| 1 | 403839 | 1173154 | 13 | 404140 | 1172372 |
| 2 | 403866 | 1173212 | 14 | 404091 | 1172562 |
| 3 | 403778 | 1173222 | 15 | 404090 | 1172679 |
| 4 | 403719 | 1173339 | 16 | 404062 | 1172722 |
| 5 | 403508 | 1173331 | 17 | 404010 | 1172770 |
| 6 | 403582 | 1173042 | 18 | 403990 | 1172826 |
| 7 | 403951 | 1172000 | 19 | 403990 | 1172888 |
| 8 | 404247 | 1172148 | 20 | 403985 | 1172938 |
| 9 | 404224 | 1172187 | 21 | 403964 | 1172976 |
| 10 | 404200 | 1172232 | 22 | 403930 | 1173003 |
| 11 | 404176 | 1172284 | 23 | 403920 | 1173089 |
| 12 | 404150 | 1172336 | | | |

**មាត្រា២.-**

ត្រូវបានកំណត់ជាតំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" លើផ្ទៃដីទំហំ៧,០៧ ហិកតា (ប្រាំពីរហិកតានិងសូន្យប្រាំពីរអា) សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានស្ថិតក្នុងភូមិសាស្ត្រភូមិព្រែកចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ដែលមានផែនទីកំណត់ទីតាំងជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងចំណុចនិយាមកាដូចខាងក្រោម៖

| No | X | Y | No | X | Y |
|---|---|---|---|---|---|
| 1 | 397665 | 1170070 | 3 | 397311 | 1170457 |
| 2 | 397617 | 1170328 | 4 | 397313 | 1170237 |



www.pheakdeylaw.com

**មាត្រា៣.-**

តំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ស្ថិតក្នុងភូមិសាស្ត្រ ភូមិទទឹងថ្ងៃ ឃុំបឹងទូក និងភូមិព្រៃកចេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងដែលបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ ចំការ។ ការចេញប័ណ្ណដីធ្លី ការអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថានដោយអនុលោមតាមច្បាប់ភូមិបាល។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

ឧបសម្ព័ន្ធៈ អនុក្រឹត្យលេខ ១៦៧ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១៧

# ផែនទីកំណត់តំបន់សហគមន៍ នៃឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» លើផ្ទៃដីទំហំ ៩១.៥៣ ហិកតា ស្ថិតក្នុងភូមិសាមគ្គី ភូមិនីងថ្ងៃ ឃុំបឹងទូក និងទំហំ ៧.០៧ ហិកតា ក្នុងភូមិព្រែកទេក ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត




| ចំណុចនិយាមកា តំបន់ A | | |
|---|---|---|
| ID | Coor_X | Coor_Y |
| 1 | 403893 | 1173154 |
| 2 | 403866 | 1173212 |
| 3 | 403778 | 1173222 |
| 4 | 403719 | 1173339 |
| 5 | 403508 | 1173331 |
| 6 | 403582 | 1173042 |
| 7 | 403951 | 1172000 |
| 8 | 404247 | 1172148 |
| 9 | 404224 | 1172187 |
| 10 | 404200 | 1172232 |
| 11 | 404176 | 1172284 |
| 12 | 404150 | 1172336 |
| 13 | 404140 | 1172372 |
| 14 | 404091 | 1172567 |
| 15 | 404090 | 1172679 |
| 16 | 404062 | 1172722 |
| 17 | 404010 | 1172770 |
| 18 | 403990 | 1172826 |
| 19 | 403990 | 1172888 |
| 20 | 403985 | 1172935 |
| 21 | 403964 | 1172976 |
| 22 | 403930 | 1173003 |
| 23 | 403970 | 1173089 |

| ចំណុចនិយាមកា តំបន់ B | | |
|---|---|---|
| ID | Coor_X | Coor_Y |
| 1 | 397665 | 1170070 |
| 2 | 397617 | 1170328 |
| 3 | 397311 | 1170457 |
| 4 | 397313 | 1170237 |



រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**